SurveyWorks!

# សំបុត្រព័ត៌មានសំរាប់មាតាបិតា/អ្នកអាណាព្យាបាល សំរាប់ការអង្កេត SurveyWorks

ជូនចំពោះមាតាបិតា/អ្នកអាណាព្យាបាល

Rhode Island Department of Elementary and Secondary Education (RIDE-ក្រសួងអប់រំផ្នែកបឋម និងមធ្យមសិក្សា នៃរ៉ូដអាយឡែនដ៍) កំពុងតែធ្វើការជាមួយនឹងសាលារៀនប្រចាំមូលដ្ឋាន និងស្គូលឌីសស្រ្ទិក របស់អ្នក ដើម្បី សិក្សាអង្កេតដល់សិស្សសាលានៅក្នុងរដ្ឋ ដែលហៅថា SurveyWorks (កិច្ចការអង្កេត)។ WestEd ដែលជាអតិថិជន របស់យើងខ្ញុំ នឹងជាអ្នករៀបចំអនុវត្តការអង្កេតនេះ តាមបែបអនឡាញ ដើម្បីជួយដល់ សាលារៀនប្រចាំមូលដ្ឋាន ស្គូលឌីសស្រ្ទិក ព្រមទាំង RIDE ធ្វើឲ្យសាលារៀនរបស់យើងមានការរីកចំរើន និងជួយជ្រោមជ្រែងបានកាន់តែប្រសើរ លើការបង្រៀន និងការរៀនសម្រាប់សិស្សគ្រប់រូប នៅ Rhode Island ។ ព័ត៌មានដែលប្រមូលបានពីការអង្កេតនេះ នឹងជួយដល់អ្នកអប់រំ ដែលកំពុងបំរើការនៅ Rhode Island ក្នុងការកែលំអកម្មវិធីសិក្សា បរិយាកាសសាលា និងកម្មវិធីផ្សេងៗទៀតប្រចាំសាលា ។ សាលារៀន ឌីសស្រ្ទិក មាតាបិតាសិស្ស និងក្រុមដែលផ្តល់ការជ្រោមជ្រែងដល់សាលា អាចប្រើលទ្ធផលពីការសិក្សាអង្កេតនេះ ដើម្បីយល់ដឹងអំពីបញ្ហា និងស្ថានភាពនានា ដែលចូលមកមានតួនាទី លើការធ្វើឲ្យសិស្ស អាចសម្រេចជោគជ័យលើការសិក្សាបាន នៅក្នុងសក្តានុពលដ៏ពេញលេញរបស់ពួកគេ ។

សិស្សរបស់ Rhode Island ទាំងអស់ ចាប់ពីថ្នាក់ទី 4 ដល់ថ្នាក់ទី12 នឹងត្រូវបានស្នើសុំឲ្យចូលរួមក្នុងការអង្កេតអនឡាញនេះ នៅតាមសាលារបស់ខ្លួន ។ ការអង្កេតនេះ មិនមានរួមបញ្ចូលការធ្វើតេស្តលើមុខវិជ្ជាសិក្សា ឬកាយសម្ព័ន្ធឡើយ ហើយត្រូវចំណាយពេលប្រហែលពី 20 ទៅ 25 នាទី ដើម្បីឆ្លើយសំណួរឲ្យបានរួចរាល់ ។ ការចូលរួមរបស់កូនអ្នក ក្នុងការអង្កេតនេះ គឺជារឿងស្ម័គ្រចិត្ត ហើយធ្វើជាលក្ខណ:អនាមិក គឺបានន័យថា មិនតម្រូវឲ្យសិស្សសរសេរឈ្មោះរបស់ខ្លួនចូលក្នុងបញ្ជីសំណួរ ឬត្រូវរាយការណ៍អំពីឈ្មោះសិស្សដែលចូលរួមឡើយ ។ ការអង្កេតនេះ មានផ្សាយនៅឯ www.surveyworks.ride.ri.gov និងនៅឯការិយាល័យរបស់សាលា សម្រាប់ឲ្យអ្នកធ្វើវិវេចនា ។

ការអង្កេតនេះ នឹងសួរសំណួរមួយចំនួនអំពី ៖

- ការត្រៀមខ្លួនរួចរាល់សំរាប់រៀននៅមហាវិទ្យាល័យ និងចូលធ្វើការ
- បរិយាកាសរបស់សាលារៀន
- ការរំពឹងទុករបស់គ្រូ
- ការជ្រោមជ្រែងពីសាលា
- ការពាក់ព័ន្ធរបស់សាលា និងសហាគមន៍
- អាហារូបត្ថម្ភ និងសកម្មភាពកាយសិក្សា
- សកម្មភាពការរៀនសូត្រ
- ស្ថានភាពអាគាររបស់សាលារៀន
- ការមានសិទ្ធិប្រើធនធាននានា
- សុវត្ថិភាពរបស់សាលា
- ការសម្លុតគំរាម
- ការជក់ថ្នាំ ការផឹកស្រា និងការប្រើគ្រឿងញៀន
- ការប្រើបច្ចេកវិជ្ជា
- ការគេចសាលា*
- សុខភាពផ្លូវចិត្ត*
- សកម្មភាពផ្លូវភេទ**

** ប្រធានបទអង្កេតសម្រាប់សិស្សអនុវិទ្យាល័យ និងវិទ្យាល័យ*

SurveyWorks!

*** ជាប្រធានបទសម្រាប់តែអង្កេតលើសិស្សវិទ្យាល័យ*

សិស្សមួយចំនួន អាចមានអារម្មណ៍មិនសុខស្រួល ក្នុងការឆ្លើយសំណួរខ្លះៗ ។ ដូច្នេះអ្នកផ្តល់ការប្រឹក្សាយោបល់ប្រចាំសាលា ឬអ្នកមានវិជ្ជាជីវៈខាងផ្នែកនេះដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងប្រចាំការ ចាំជួយដល់សិស្សរូបណាដែលមានអារម្មណ៍មិនសុខស្រួល ឬសម្រាប់ជួយដល់សិស្សណាដែលមានបំណងដើម្បីពិភាក្សាគ្នាលើសំណួរ ឬប្រធានបទណាមួយ ។

ការបានទទួលលទ្ធផល ដែលអាចជាតំណាងសាលារៀនរបស់កូនអ្នក អាស្រ័យលើការមានសិស្សមួយចំនួនធំ ចូលរួមតាមដែល អាចធ្វើទៅបាន ។ អ្នកអាចឲ្យកូនរបស់ខ្លួនចាកចេញពីការអង្កេតនេះបានគ្រប់ចំណុចទាំងអស់ ក្នុងដំណើរការនៃការឆ្លើយសំណួរ ដោយគ្មានការទទួលការពិន័យអ្វីឡើយ ។ បើកូនរបស់អ្នកសុខចិត្តចូលរួមក្នុងការអង្កេតនេះ ពួកគេមាន សិទ្ធិរំលងសំណួរណាមួយចោល ដែលពួកគេមិនចង់ឆ្លើយបាន ឬមួយថែមទាំងអាចដកខ្លួនចេញពីការអង្កេតបានទៀតផង ។

ប្រសិនបើអ្នកមានមូល់បន្ថែមអំពីការអង្កេតនេះ សូមទំនាក់ទំនងជាមួយ SurveyWorks Help Desk (អ្នកផ្តល់ជំនួយលើកិច្ចការអង្កេត) ពីរវាងម៉ោង 8 ព្រឹក ដល់ម៉ោង 4 ល្ងាច EST (ម៉ោងរបស់ឆ្នេរខាងកើត) តាមរយៈលេខ 1-877-787-5725 ឬអ៊ីម៉េល surveyworks@wested.org ។ សម្រាប់ចម្ងល់ ឬការព្រួយបារម្ភនានាអំពីសិទ្ធិរបស់កូនអ្នក ក្នុងនាមជាអ្នកឆ្លើយសំណួរអង្កេត អ្នកអាចទំនាក់ទំនងជាមួយ WestEd’s Office of Research Integrity (ការិយាល័យ WestEd ផ្នែកភាពស្មោះត្រង់ លើការសិក្សាស្រាវជ្រាវ) តាមរយៈលេខ (877) 493-7833 លេខបន្ត 3202 ឬអ៊ីម៉េល subjects@wested.org ដើម្បីបានដឹងព័ត៌មានបន្ថែមអំពី WestEd សូមទស្សនាគេហទំព័រ www.wested.org ។

ប្រសិនបើអ្នកមិនចង់ឲ្យកូនរបស់ខ្លួនចូលរួមក្នុងការអង្កេតនេះទេ សូមបំពេញបែបបទដែលមានភ្ជាប់មកជាមួយ ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ។ សាលារៀន នឹងសន្មតថា អ្នកអនុញ្ញាតឲ្យកូនរបស់អ្នកចូលរួមក្នុងការអង្កេត បើអ្នកមិនផ្ញើបែបបទនេះត្រឡប់មកវិញ ឲ្យបានមុនថ្ងៃទី 19 ខែមករា 2012 ទេនោះ ។ បើអ្នកចង់ផ្លាស់ប្តូរចិត្ត បន្ទាប់ពីអំឡុងពេលនោះ អ្នកអាចផ្ញើអ៊ីម៉េល ឬហៅទូរស័ព្ទមកកាន់សាលារៀន ដើម្បីជូនដំណឹងឲ្យពួកគេបានដឹង ។ អ្នកអាចបញ្ជូនបែបបទនេះទៅកាន់ ការិយាល័យរបស់សាលាដោយផ្ទាល់ តាមប្រៃសនីយ ឬឲ្យកូនរបស់អ្នកយកវាមកសាលាជំនួសរូបអ្នកបាន ។ សូមប្រាប់កូនរបស់អ្នកឲ្យបានដឹងថា ពួកគេនឹងត្រូវចូលរួម ឬមិនត្រូវចូលរួមលើការអង្កេតនេះ ។ បើអ្នកមិនឲ្យ កូនរបស់ខ្លួនចូលរួមក្នុងការអង្កេតនេះទេ ពួកគេនឹងត្រូវធ្វើកិច្ចការផ្សេងចំពោះការសិក្សា ក្នុងអំឡុងពេលដែលសិស្សដទៃ ឆ្លើយសំណួរការអង្កេត ។ សូមអរគុណចំពោះកិច្ចសហប្រតិបត្តិការរបស់អ្នក ក្នុងកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់មួយនេះ ។

SurveyWorks!

# ការអង្កេត SurveyWorks ចំពោះសិស្ស ឆ្នាំ 2011-2012

## បែបបទសុំមិនចូលរួម

ចូរបំពេញបែបបទ**នេះ** ប្រសិនបើអ្នក **មិន** មានបំណងឲ្យកូនរបស់ខ្លួន ចូលរួមក្នុងការអង្កេតនេះ ។ សូមបញ្ជូនបែបបទនេះត្រឡប់មកកាន់សាលារៀនរបស់កូនអ្នក ឲ្យបានមុនថ្ងៃទី 19 ខែមករា ឆ្នាំ2012 ។

---

ខ្ញុំ **មិនអនុញ្ញាតឲ្យ** កូនរបស់ខ្ញុំចូលរួមក្នុងការអង្កេត SurveyWorks ចំពោះសិស្ស ឆ្នាំ 2011-2012 នេះទេ ។ ខ្ញុំដឹងថាកូនរបស់ខ្ញុំ នឹងត្រូវបានសាលាចាត់ឲ្យធ្វើសកម្មភាពផ្សេង ក្នុងពេលដែលសិស្សដទៃចូលរួមឆ្លើយសំណួរអង្កេតនេះ ។

ឈ្មោះរបស់សិស្ស (សូមសរសេរជាអក្សរពុម្ព) ៖________________________________________

ឈ្មោះសាលារៀនរបស់សិស្ស (សូមសរសេរជាអក្សរពុម្ព) ៖____________________ថ្នាក់ទី ៖_________

ហត្ថលេខារបស់មាតាបិតា ឬអ្នកអាណាព្យាបាល ៖________________________________________

សូមបញ្ជូនទំព័រនេះ ទៅកាន់ការិយាល័យសាលារៀនរបស់កូនអ្នក **ក្នុងករណី** ដែលអ្នក **មិន** មានបំណងឲ្យកូនរបស់ខ្លួនចូលរួមក្នុងការអង្កេត ។ បើអ្នកអនុញ្ញាតឲ្យកូនរបស់អ្នកចូលរួមក្នុងការអង្កេតនេះ អ្នក **មិន** ចាំបាច់បញ្ជូនបែបបទនេះត្រឡប់មកវិញទេ ។ យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការជួយរបស់អ្នក លើការអង្កេតដ៏មានសារៈសំខាន់មួយនេះ ។